**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៣៦៦៦ សហវ.អវ

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៥

**ជម្រាបជូន**
**លោក លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត**

**កម្មវត្ថុ**: សំណើសុំផ្អាកជាបណ្តោះអាសន្នលើការទិញរថយន្តរបស់មន្ទីរជំនាញរាជធានី ខេត្ត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូមលោក លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្តជ្រាបថា: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលព័ត៌មានជាបន្តបន្ទាប់ថា កន្លងមកមន្ទីរជំនាញរាជធានី ខេត្ត ជាច្រើនបានស្នើសុំជានាចំណាយ ដើម្បីអនុវត្តនីតិវិធីលទ្ធកម្មទិញរថយន្ត សម្រាប់បម្រើការងាររដ្ឋបាលរបស់ខ្លួន។

ករណីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងពិនិត្យ បូកសរុបសំណើទាំងអស់ជាកញ្ចប់រួមមួយ ដើម្បីស្នើសុំការសម្រេចរបស់រាជរដ្ឋាភិបាលជាមុនសិន។

ក្នុងន័យនេះ សូមលោក លោកស្រី មេត្តាជូនដំណឹងដល់មន្ទីរជំនាញរាជធានី ខេត្ត ទាំងអស់ អំពីចំណាត់ការនេះជាការប្រញាប់។

សូមលោក លោកស្រី ទទួលនូវការគោរពរាប់អានពីខ្ញុំ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

ចម្លងជូន:
- សាលារាជធានី ខេត្ត
- គ្រប់មន្ទីររាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ